**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ....១៤...ប.ទ...ស.ង.ក...........

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបញ្ឈប់ការធ្វើអាជីវកម្មលើវិស័យប្រៃសណីយ៍ ដោយគ្មានអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ឱ្យបានជ្រាបថា អនុលោមតាមច្បាប់ស្តីពីវិស័យប្រៃសណីយ៍ និងលិខិតបទដ្ឋាននានា អាជីវកម្មប្រៃសណីយ៍គ្រប់ប្រភេទនៃព្រះរាជាណាចក្រកម្ពុជាត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។ ម្ចាស់អាជីវកម្មក្នុងវិស័យប្រៃសណីយ៍គ្រប់រូបតម្រូវឱ្យមានអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតជាដាច់ខាតដើម្បីប្រកបអាជីវកម្ម។

នាពេលកន្លងទៅ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានសង្កេតឃើញថា ម្ចាស់អាជីវកម្មមួយចំនួននៅមិនទាន់គោរពបាននូវលក្ខខណ្ឌនៃអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតគ្រប់ជ្រុងជ្រោយនៅឡើយ។ ម្ចាស់អាជីវកម្មខ្លះកំពុងប្រកបអាជីវកម្មរបស់ខ្លួនដោយគ្មានអាជ្ញាបណ្ណ និងលិខិតអនុញ្ញាតមានសុពលភាពពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដែលទង្វើនេះផ្ទុយទៅនឹងបទប្បញ្ញត្តិនៃមាត្រា២៤ និងមាត្រា៤៨ នៃច្បាប់ស្តីពីវិស័យប្រៃសណីយ៍។ *"ម្ចាស់អាជីវកម្មដែលគ្មានអាជ្ញាបណ្ណអាចនឹងត្រូវបញ្ឈប់អាជីវកម្មដោយបន្ទាន់ និងត្រូវពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល។ ករណីមិនរាងចាលនឹងត្រូវបញ្ជូនសំណុំរឿងទៅតុលាការ។"*

ក្នុងគោលដៅជំរុញឱ្យការគ្រប់គ្រងវិស័យប្រៃសណីយ៍ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព សណ្តាប់ធ្នាប់ និងការពារបាននូវផលប្រយោជន៍អ្នកប្រើប្រាស់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ សូមជូនដំណឹងដល់ម្ចាស់អាជីវកម្មដែលកំពុងធ្វើប្រតិបត្តិការក្នុងវិស័យប្រៃសណីយ៍ទាំងអស់ចូលរួមសហការដូចខាងក្រោម៖

១. ចំពោះម្ចាស់អាជីវកម្ម ដែលពុំទាន់មានអាជ្ញាបណ្ណសម្រាប់ស្នាក់ការកណ្តាល និងលិខិតអនុញ្ញាតឱ្យបើកសាខាដែលមានទីតាំងនៅរាជធានីភ្នំពេញ ត្រូវស្នើសុំមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

២. ចំពោះម្ចាស់អាជីវកម្ម ដែលពុំទាន់មានលិខិតអនុញ្ញាតឱ្យបើកសាខាដែលមានទីតាំងតាមបណ្តាខេត្ត ត្រូវស្នើសុំមកកាន់មន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត ដែលសាខានោះតាំងនៅ។

ម្ចាស់អាជីវកម្មដែលមិនទាន់បានបំពេញតាមបទប្បញ្ញត្តិខាងលើ ត្រូវរួសរាន់មកដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និង/ឬលិខិតអនុញ្ញាត យ៉ាងយូរបំផុតឱ្យបានត្រឹម**ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២១** ជាកំហិត។

សម្រាប់ព័ត៌មានបន្ថែម ដើម្បីស្នើសុំអាជ្ញាបណ្ណ និងលិខិតអនុញ្ញាត សូមធ្វើការទាក់ទងមកអគ្គនាយកដ្ឋានប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ តាមរយៈទូរសព្ទលេខ ០៧០ ៩៧២ ៧០៧/០១២ ៧៣៤ ៣៧៥/០១៨ ៥៩៥៩ ៨៥៨ ឬអ៊ីម៉ែល gdpadmin@mptc.gov.kh។

ថ្ងៃពុធ ១២ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី១០ខែមីនា ឆ្នាំ២០២១

ស្កេន QR Code

ដើម្បីទាញយកទម្រង់ពាក្យស្នើសុំនិងឯកសារពាក់ព័ន្ធ